៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---------

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៥៨ អ.ន.ក្រ

# អនុក្រឹត្យ

## ស្ដីពី

## ការបង្កើតគណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តមសីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត១០៩៤.៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤
- តាមសំណើរបស់ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សំរេច :

### មាត្រា១

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការវាយតំលៃដីមិនបានប្រើប្រាស់ ដែលមានសមាសភាពដូចខាងក្រោម :

- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ អ្នកតំណាងជាប្រធាន

- ប្រធានគណៈកម្មាធិការជាតិរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ឬ អ្នកតំណាងជាអនុប្រធាន
- ប្រធាននាយកដ្ឋានពន្ធដារ ឬ អ្នកតំណាងជាសមាជិក
- ប្រធាននាយកដ្ឋានទ្រព្យរដ្ឋ ឬ អ្នកតំណាងជាសមាជិក
- ប្រធាននាយកដ្ឋានសុរិយោដី ឬ អ្នកតំណាងជាសមាជិក

មាត្រា២ _

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម
- រៀបចំបញ្ជីរាយនាមអចលនទ្រព្យ និង កំណត់តម្លៃលក់ ឬជួល
- កំណត់ប្រចាំឆ្នាំនូវតម្លៃដីក្នុងក្រុងខេត្ត
- ផ្តល់មតិចំពោះរឿងវិវាទ

មាត្រា៣ _

គណៈកម្មការនេះមានសិទ្ធិចាត់តាំងអនុគណៈកម្មការនៅតាមខេត្តក្រុងនីមួយៗ សំរាប់ជំនួយការក្នុងការអនុវត្តន៍ភារកិច្ចខាងលើ ។

មាត្រា៤ _

គណៈកម្មការវាយតម្លៃអចលនទ្រព្យ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន ។

មាត្រា៥ _

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងអស់លោកដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានិងចុះហត្ថលេខាតទៅ ។

<u>កន្លែងចំលង</u>៖
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- គ្រប់សាលាខេត្ត_ក្រុង
- ដូចក្នុងមាត្រា៥ "ដើម្បីអនុវត្ត"
- ឯកសារ_កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ១៩៩៥

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

នរោត្តម រណឫទ្ធិ ហ៊ុន សែន

លេខ 005 ចល.សបរ.ចធ

ជាសេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី 26 ខែ កក្កដា ឆ្នាំ១៩៩៥

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត់ ឆន